ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ៣១ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I ខុទ្ទកាល័យព្រះមហាក្សត្រ

១—ព្រះរាជក្រឹត្យ

០៨.៧.៩៦	ព្រះរាជក្រឹត្យ ជស/រកត/០៧៩៦/៣២ តែងតាំងឯកឧត្តម សំ សុខផល ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ឡូយ ស៊ីមឈាង អនុប្រធានទី ១ នៃរដ្ឋសភា	១៣៤៩
០៨.៧.៩៦	ព្រះរាជក្រឹត្យ ជស/រកត/០៧៩៦/៣៣ តែងតាំងឯកឧត្តម អ៊ុង សុផល ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ឡូយ ស៊ីមឈាង អនុប្រធានទី ១ នៃរដ្ឋសភា	១៣៥០
០៨.៧.៩៦	ព្រះរាជក្រឹត្យ ជស/រកត/០៧៩៦/៣៤ តែងតាំងឯកឧត្តម ស៊ុយ ម៉ុងលាង ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ឡូយ ស៊ីមឈាង អនុប្រធានទី ១ នៃរដ្ឋសភា	១៣៥១
០៨.៧.៩៦	ព្រះរាជក្រឹត្យ ជស/រកត/០៧៩៦/៣៥ តែងតាំងឯកឧត្តម ចាន់ ឆាយហេង ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ឡូយ ស៊ីមឈាង អនុប្រធានទី ១ នៃរដ្ឋសភា	១៣៥២
១៤.៨.៩៦	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៦/៣៩ តែងតាំងឯកឧត្តម ជា វិទ្ធីឈុត ជាប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុងកែបមានឋានៈស្មើ អនុរដ្ឋលេខាធិការ	១៣៥៣
១៩.៨.៩៦	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៦/៦១ តែងតាំងលោក តាន់ ឈុន ជា ឧកញ៉ា	១៣៥៤

II ឯកសារគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

១៩.៨.៩៦ អនុក្រឹត្យលេខ ១៤៩ អនក្រ.តត ស្តីពីការផ្ទេរមេដាយស្ថាបនាជាតិ ១៣៥៥

២— សេចក្តីសំរេច

២០.៨.៩៦ សេចក្តីសំរេចលេខ ៣៤ សសរ ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់សំរួលដោះស្រាយជួយឧបត្ថម្ភដល់បងប្អូនមករួមរស់ក្នុងសង្គមជាតិទិសពាយ័ព្យ ១៣៥៦

III ការងារបណ្តាក្រសួង

១—ឯកសាររដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រកាស

១៦.៨.៩៦ ប្រកាសលេខ ៣០៩ សហវ.ប្រក.តរ ស្តីពីការកំណត់បទដ្ឋានហួតហើរដឹកជញ្ជូនលើផលិតផល តេលសិលា ១៣៦២
២១.៨.៩៦ ប្រកាសលេខ ៣១៨ ប្រកសហវ.ពជ ស្តីពីការបំពេញបន្ថែមប្រការ ៤ នៃប្រកាសលេខ ៣៣២ ប្រក.សហវ.ពជ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីកាន់ការបញ្ជីចំណូល–ចំណាយ ១៣៦៤
២១.៨.៩៦ ប្រកាសលេខ ៣១៩ ប្រកសហវ.ពជ ស្តីពីនីតិវិធីអនុវត្តសិទ្ធិធ្វើអង្កេត ១៣៦៦
២២.៨.៩៦ ប្រកាសលេខ ៣២៣ ប្រក.សហវ.តរ ស្តីពីការតែងតាំងមន្ត្រីរាជការ ១៣៧១

២—ឯកសាររដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

២០.៨.៩៦ ប្រកាសលេខ ៥០០ ផក.ប្រក អនុញ្ញាតអោយលោក សុខ លី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតពោះវៀនកង់–ម៉ូតូ សញ្ញា « សំពៅ » ១៣៧២
២០.៨.៩៦ ប្រកាសលេខ ៥០១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ម៉ិល ស៊ីម៉េង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ ១៣៧៣
២០.៨.៩៦ ប្រកាសលេខ ៥០២ ផក.ប្រក អនុញ្ញាតអោយលោកម៉ិល មង្គុន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៣៧ សេះ ១៣៧៣
២០.៨.៩៦ ប្រកាសលេខ ៥០៣ ផក.ប្រក អនុញ្ញាតអោយលោក សោម សុខុន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ១៣៧៤

៣–ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

២៣.៨.៩៦ ប្រកាសលេខ ៧០១ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅ ជីវវិទ្យា សំរាប់គ្រូថ្នាក់ទី ៧ ១៣៧៤
២៣.៨.៩៦ ប្រកាសលេខ ៧០២ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅ ភាសាខ្មែរ សំរាប់គ្រូថ្នាក់ទី ៧ ១៣៧៦

៤–ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

១៦.៨.៩៦ សេចក្តីសំរេចលេខ ១៥៧/៩៦ កធស អនុញ្ញាតជាគោលការណ៍អោយមានព្រះវិហារចិនឈ្មោះ « សាមអ៊ីង » ស្ថិតនៅ ភូមិពន្ធា សង្កាត់ព្រែកប្រា ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ១៣៧៧

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៧៩៦/៣២

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង
កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីសំរេចរបស់រដ្ឋសភាស្តីពីការជ្រើសតាំងសម្តេច **ជា ស៊ីម** ជាប្រធានរដ្ឋសភា ឯកឧត្តម **ឡូយ ស៊ីមឈាង** ជាអនុប្រធានទី ១ នៃរដ្ឋសភា នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភាស្តីទី ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **សំ សុខផល** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម **ឡូយ ស៊ីមឈាង** អនុប្រធានទី ១ នៃរដ្ឋសភា នៃ ព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៧៩៦/៣៣

យើង

ព្រះបាទសម្ដេច ព្រះនរោត្ដម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្ដម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្ដីសំរេចរបស់រដ្ឋសភា ស្ដីពីការជ្រើសតាំងសម្ដេច **ជា ស៊ីម** ជាប្រធានរដ្ឋសភា ឯកឧត្ដម **ឡូយ ស៊ីមឈាង** ជាអនុប្រធានទី ១ នៃរដ្ឋសភានាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភាស្ដីទី ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្ដម **អ៊ុន សុផល** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្ដម **ឡូយ ស៊ីមឈាង** អនុប្រធានទី ១ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះក្លាយជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦
ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៧៩៦/៣៤

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង
កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- យោងតាមសេចក្តីសំរេចរបស់រដ្ឋសភា ស្តីពីការជ្រើសតាំងសម្តេច **ជា ស៊ីម** ជាប្រធានរដ្ឋសភា ឯកឧត្តម **ឡូយ ស៊ីមឈាង** ជាអនុប្រធានទី ១ នៃរដ្ឋសភានាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភាស្តីទី ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ :តែងតាំងឯកឧត្តម **ស៊ុយម៉ុងសាង** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម **ឡូយ ស៊ីមឈាង** អនុប្រធានទី ១ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាមានឋានៈតេ រដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអ លេខាធិការរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរា ក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៧៩៦/៣៥

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- យោងតាមសេចក្តីសំរេចរបស់រដ្ឋសភា ស្តីពីការជ្រើសតាំងសម្តេច ជា ស៊ីម ជាប្រធានរដ្ឋសភាឯកឧត្តម **ឡូយ ស៊ីមឈាង** ជាអនុប្រធានទី ១ នៃរដ្ឋ

សភាជាតិសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣

-យោងតាមសំណើរបស់ប្រធានរដ្ឋសភាស្ដីទី ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ចាន់ សារ៉េងហេង ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម **ឡូយ ស៊ីមឈាង** អនុប្រធានទី ១ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាមានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៨៩៦/៥៩

យើង

ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * * *

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ

វិច្ឆិកា ឆ្នាំ ១៩៩៣

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ជា រិទ្ធីឃុត** ជាប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុងកែបមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យនស/រកត/០៨៩៦/៦១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក តាន់ ឈុន

ជា

ឧកញ៉ា

ភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

II ឯកសារគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ: ១៤៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រ កម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិតាមលំដាប់ថ្នាក់ជូនចំពោះសប្បុរសជនខ្មែរ នៅក្នុងនិងក្រៅប្រទេស ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគទ្រព្យសម្បត្តិចូលរួមជួយ កសាងសមិទ្ធផលផ្សេង ៗ ជូនជាតិ នៅក្នុងមូលដ្ឋានខេត្តបាត់ដំបង ដូចមានរាយ នាមខាងក្រោមនេះ ÷

ក_មេដាយមាសស្ថាបនាជាតិ :

១_សមាគមសប្បុរសជនខ្មែររស់នៅក្រៅប្រទេស បរិច្ចាគទឹកប្រាក់ចំនួន ៩៤.៦៦៩ $US

២_ប្រជាពលរដ្ឋ ឃុំស្ពោ ស្រុកបាត់ដំបង បរិច្ចាគទឹកប្រាក់ចំនួន ១៥.៩០៩ $US

៣_លោក **សាំ ឌិន** នៅសហរដ្ឋអាមេរិក បរិច្ចាគទឹកប្រាក់ចំនួន ១៥.៨៨៥ $US

៤_លោកព្រាប ឱុយឈោ និងលោកស្រី **សុខ យឿត** បរិច្ចាគទឹកប្រាក់ចំនួន ១២.១៨០ $US

ខ_មេដាយប្រាក់ ស្ថាបនាជាតិ :

១_លោកយាយ ឌៃ **ឌីទ** នៅសហរដ្ឋអាមេរិក បរិច្ចាគទឹកប្រាក់ចំនួន ៩.២០០ $US

២_លោក **ជា ឡើ** និងអ្នកស្រី **ខា ឡៀង** នៅក្រុងបាត់ដំបង បរិចាគទឹកប្រាក់ចំនួន ៦.២៦០ $US

គ_មេដាយសំរិទ្ធស្ថាបនាជាតិ :

១_សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ដឹកនាំដោយលោក **សាំ ឌិន** បរិច្ចាគទឹកប្រាក់ចំនួន១.៦០០ $US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២—សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្តីលេខ: ៣៤ សសរ

ស្តីពីការបង្កើតគណៈកម្មាធិការសំរបសំរួលដោះស្រាយជួយឧបត្ថម្ភដល់បងប្អូនមករួមរស់ក្នុងសង្គមជាតិនិងសពាយ័ព្យ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ ស្តីពីការបង្កើតអង្គភាពសំរបសំរួលបញ្ជាកងទ័ពរំសាយ និងសមាហរណកម្មចូលក្នុងសង្គមជាតិ នូវអតីតទាហានខ្មែរក្រហម ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៥
- តាមសំណើរបស់អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មាធិការសំរាប់សំរួលដោះស្រាយ ជួយឧបត្ថម្ភដល់បងប្អូនមករួមរស់ក្នុងសង្គមជាតិទិសពាយ័ព្យ ដែលមានសមាសភាពដូចខាងក្រោម ÷

១_ឯកឧត្តមឧត្តមសេនីយ៍ឯក **កែ គីមយ៉ាន** នាយអគ្គសេនាធិការ ជាប្រធាន

២_ឯកឧត្តមឧត្តមសេនីយ៍ឯក **ញឹក ប៊ុនឆៃ**នាយអគ្គសេនាធិការរងទី១ ជាអនុប្រធាន

៣_ឯកឧត្តមឧត្តមសេនីយ៍ឯក**ប៉ុលសារឿន**នាយអគ្គសេនាធិការរង ជាអនុប្រធាន

៤_ឯកឧត្តមឧត្តមសេនីយ៍ទោ **លី សេងហុង** នាយអគ្គសេនាធិការរង ជាអនុប្រធាន

៥_ឯកឧត្តមឧត្តមសេនីយ៍ទោ **ហ៊ុល សាវ័ន្ត**មេបញ្ជាការយោធភូមិភាគទី ៥ សមាជិក

៦_ឯកឧត្តមឧត្តមសេនីយ៍ទោខាន់ **សោះឡឹង្គ**មេបញ្ជាការយោធភូមិភាគទី ៤ សមាជិក

៧_ឯកឧត្តមឧត្តមសេនីយ៍ទោ **ម៉ែន ប៊ុនថន** នាយកទីចាត់ការចលនូបត្ថម្ភ សមាជិក

៨_ឯកឧត្តមឧត្តមសេនីយ៍ទោ **សារ៉ែត ឌី** មេបញ្ជាការយោធភូមិភាគទី ៣ សមាជិក

៩_ឧត្តមសេនីយ៍ទោ **អេន ស៊ុំ** នាយកមជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រ យោធាអគ្គបញ្ជាការដ្ឋាន សមាជិក

១០_ឧត្តមសេនីយ៍ទោ **ជា សារ៉ន** នាយកការិយាល័យទី ៣អគ្គសេនាធិការ សមាជិក

១១_ឧត្តមសេនីយ៍ត្រី **ម៉ុង សំផន** នាយកនាយកដ្ឋានថវិកាក្រសួងការពារជាតិ សមាជិក

១២_ឧត្តមសេនីយ៍ត្រី **ស៊ុំ សំណាង** នាយកនាយកដ្ឋានផ្គត់ផ្គង់ក្រសួងការពារជាតិ សមាជិក

១៣_ឧត្តមសេនីយ៍ត្រី **ចៅ តិរុណ** នាយក.នាយកដ្ឋានសំភារៈបច្ចេទេស ក្រសួងការពារជាតិ សមាជិក

១៤_ឧត្តមសេនីយ៍ត្រី **ផុនសាវ៉ាត** នាយករងអន្តរាគមន៍អគ្គសេនាធិការ សមាជិក

១៥_ឧត្តមសេនីយ៍ត្រី **ព្រាប តាន់** នាយកការិយាល័យទី ៥ អគ្គសេនាធិការ សមាជិក

១៦_ឧត្តមសេនីយ៍ត្រី **គីម ម៉ិនធឿន** នាយរងការិយាល័យទី ៣ អគ្គ សេនាធិការ សមាជិក

១៧_ឧត្តមសេនីយ៍ត្រី **ម៉ក់ សារុន** នាយកការិយាល័យទី ៤ អគ្គសេនាធិការ សមាជិក

១៨_ឧត្តមសេនីយ៍ត្រី **មាស ថន** នាយកការិយាល័យយោធាតំបន់អគ្គសេនាធិការ សមាជិក

១៩_ឧត្តមសេនីយ៍ត្រី **ស៊ុំ គីមស៊ុន** នាយករងទីចាត់ការកលយុទ្ធអគ្គបញ្ជាការដ្ឋាន សមាជិក

២០_ឧត្តមសេនីយ៍ត្រី **កែវ ពន្លឺ** មេបញ្ជាការរងយោធភូមិភាគទី ៣ សមាជិក

២១_ឧត្តមសេនីយ៍ត្រី **ខឹម ជាសារឿន** មេបញ្ជាការរងយោធភូមិភាគទី ៣ សមាជិក

២២_ឧត្តមសេនីយ៍ត្រី **ខ្វាន់ ស៊ាម** មេបញ្ជាការរងវិស្វកម្មអគ្គសេនាធិការ សមាជិក

២៣_ឧត្តមសេនីយ៍ត្រី **យ៉ឹម សារី** នាយក នាយកដ្ឋានប្រេងក្រសួងការពារជាតិ សមាជិក

២៤_ឧត្តមសេនីយ៍ត្រី **ហេង ហុង** នាយក នាយកដ្ឋានវិស្វកម្មក្រសួងការពារជាតិ សមាជិក

២៥_ឧត្តមសេនីយ៍ត្រី **ជា សត្ថា** នាយកការិយាល័យទី ២ អគ្គសេនាធិការ សមាជិក

២៦_វរសេនីឯក **ដុម ហាក់** នាយរងការិយាល័យទី ២ អគ្គសេនាធិការ សមាជិក

២៧_វរសេនីយ៍ទោ **កុយ វេវាក** ការិយាល័យទី ១ អគ្គសេនាធិការ សមាជិក

២៨_វរសេនីយ៍ទោ **ម៉ែក មុន្នី** នាយរងក្រុមបញ្ជូនសារអគ្គសេនាធិការ សមាជិក

២៩_វរសេនីយ៍ឯក **ឆាន់ ធឿន** នាយរងសេនាធិការយោធភូមិភាគទី ៥ សមាជិក

ប្រការ ២ : គណៈកម្មាធិការសំរាប់សំរួលដោះស្រាយ ជួយឧបត្ថម្ភដល់បងប្អូនមកឋរស់ក្នុងសង្គមជាតិទិសពាយ័ព្យ មានគណៈកម្មាធិការអចិន្ត្រៃយ៍ដូចខាងក្រោម ÷

១_ឯកឧត្តមឧត្តមសេនីយ៍ឯក **កែ គឹមយ៉ាន** នាយអគ្គសេនាធិការ ជាប្រធាន

២_ឯកឧត្តមឧត្តមសេនីយ៍ឯក **ញឹក ប៊ុនឆៃ** នាយអគ្គសេនាធិការរងទី ១ អនុប្រធាន

៣_ឯកឧត្តមឧត្តមសេនីយ៍ឯក **ប៊ុល សារឿន** នាយអគ្គសេនាធិការរង អនុប្រធាន

៤_ឯកឧត្តមឧត្តមសេនីយ៍ទោ **ឈី សេងហុង** នាយអគ្គសេនាធិការរង អនុប្រធាន

៥_ឧត្តមសេនីយ៍ទោ ហ៊ុល សារ៉ន មេបញ្ជាការយោធភូមិភាគទី ៥ សមាជិក

៦_ឧត្តមសេនីយ៍ទោ ខាន់ សាវឿន មេបញ្ជាការយោធភូមិភាគទី ៤ សមាជិក

៧_ឧត្តមសេនីយ៍ទោ ស៊ាន ឌី មេបញ្ជាការយោធភូមិភាគទី ៣ សមាជិក

៨_ឧត្តមសេនីយ៍ត្រី ស៊ូ គីមស៊ុន នាយករងទីភាត់ការកលៈយុទ្ធអគ្គបញ្ជាការដ្ឋាន សមាជិក

៩_ឧត្តមសេនីយត្រី កែវ ពង្ស មេបញ្ជាការរងយោធភូមិភាគទី ៣ សមាជិក

ប្រការ ៣ : គណៈកម្មាធិការសំរាប់សំរួលដោះស្រាយជួយឧបត្ថម្ភដល់បងប្អូន រួមរស់ក្នុង សង្គមជាតិ ទិសពាយ័ព្យ មានភារកិច្ចដូចខាងក្រោម ÷

_ធ្វើជាសេនាធិការអោយរាជរដ្ឋាភិបាល គ្រប់កិច្ចការដែលទាក់ទងទៅនឹងបងប្អូនស្ម័គ្រចិត្តត្រឡប់មករួមរស់ក្នុងសង្គមជាតិវិញ ។

_ទំនាក់ទំនងជាមួយស្ថាប័នជាតិ អង្គការក្រៅរដ្ឋាភិបាល និង អន្តរជាតិ ដើម្បីស្វែងរកប្រភពជំនួយ ជួយកសាងជីវភាពរស់នៅរបស់បងប្អូនអោយមានស្ថេរភាព ។

_លើករាល់គំរោងសេចក្តីត្រូវការផ្គត់ផ្គង់ដល់បងប្អូន ដែលបានមករួមរស់ក្នុងសង្គមជាតិវិញចាប់ពីថ្ងៃដំបូង តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល កំណត់ ។

_យកចិត្តទុកដាក់ និង ជួយធ្វើការអប់រំ ហ្វឹកហ្វឺនដល់បងប្អូន ដើម្បីអោយយល់ដឹង អំពីគោលនយោបាយរបស់រាជរដ្ឋាភិបាល និង របៀបរស់នៅថ្មីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

_ខិតខំធ្វើការផ្សព្វផ្សាយនូវគោលនយោបាយបង្រួបបង្រួមជាតិរបស់រាជរដ្ឋាភិបាល អោយបានជាអតិបរមា ដើម្បីអូសទាញអ្នកដែលនៅសេសសល់ក្នុងជួរពួកឧទ្ទាមអោយត្រឡប់ មកក្នុងសង្គមជាតិអោយអស់ជាស្ថាពរ ។

_ជួយរៀបចំកំលាំងរបស់បងប្អូនចូលក្នុងក្របខ័ណ្ឌ នៃកងយោ..ពល

ខេមរភូមិន្ទ ។

-ធ្វើរបាយការណ៍តាមកាលកំណត់ជូនអគ្គសេនាធិការ ក្រសួងការពារជាតិអគ្គបញ្ជាការ និងអង្គភាពសំរាប់សំរបសំរួលបញ្ហាកងទ័ពរំសាយ និងសមាហរណកម្មចូលក្នុងសង្គមជាតិវិញ នូវអតីតទាហានខ្មែរក្រហម ដើម្បីរាយការណ៍ថ្វាយ និង ជូនរាជរដ្ឋាភិបាល ។

ប្រការ ៤ : គណៈកម្មាធិការសំរាប់សំរួលដោះស្រាយជួយឧបត្ថម្ភនេះ ចែកជាអនុគណៈកម្មាធិការ ២ គឺ :

-អនុគណៈកម្មាធិការទី ១ ទទួលបន្ទុកតំបន់ ចាប់ពីផ្លូវជាតិលេខ ៥ មកទិសខាងត្បូង មានឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ុល សារឿន** ជាប្រធាន ។

-អនុគណៈកម្មាធិការទី ២ ទទួលបន្ទុកតំបន់ ចាប់ពីផ្លូវជាតិលេខ ៥ ទៅទិសខាងជើង មានឯកឧត្តមឧត្តមសេនីយ៍ទោ **ខាន់ សាវឿន** ជាប្រធាន ។

សមាសភាពនៃអនុគណៈកម្មាធិការនីមួយ ៗ អាស្រ័យដោយប្រធានអនុគណៈកម្មាធិការរៀបចំ និង ដាក់ជូនប្រធានគណៈកម្មាធិការសំរេច ។

ប្រការ ៥ : គណៈកម្មាធិការមានសិទ្ធិប្រើប្រាស់ត្រា អគ្គសេនាធិការ ដើម្បីធ្វើកិច្ចការជាផ្លូវការ ។

ប្រការ ៦ : គណៈកម្មាធិការសំរាប់សំរួលដោះស្រាយជួយឧបត្ថម្ភ ត្រូវធ្វើគំរោង ស្នើ ថវិកាដែលចាំបាច់ត្រូវចំណាយសំរាប់ការងារនេះមករាជរដ្ឋាភិបាល ដោយគិតចូលក្នុងជំពូកចំណាយរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

III ការងារបណ្ដាក្រសួង

១—ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣០៩ សហវ.ប្រក.គរ

ស្ដីពីការកំណត់បនដ្ឋានហួតហើរ

ដឹកជញ្ជូនឈើផលិតផលគេលសិលា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រី ទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋនិងហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជ ក្រម នស_រកម ០១៩៦_១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ

១៩៩៦

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ១៩៩៥ ស្តីពីប្រកាសអោយប្រើច្បាប់ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញប្រកាសណែនាំនិងកំរោត់ការអនុវត្តច្បាប់ ស្តីពីអាករពិសេសលើទំនិញមួយចំនួនចំពោះទំនិញនាំចូលលេខ ៣២៩ សហវ.ប្រក.គរ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥

កំណត់

ប្រការ ១ : ដើម្បីធានាបានលើការគ្រប់គ្រងផលិតផលគេលសិលាដែលនាំ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានសុក្រឹត្យនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណត់នូវការហួតហើរចំពោះប្រេង ឥន្ធនៈដូចខាងក្រោម ÷

- ប្រេងម៉ាស៊ូត (DO) 0,២៥ ភាគរយ
- ប្រេងសាំង (EA) 0,៣៥ ភាគរយ
- ប្រេងកាត (KO) 0,២៥ ភាគរយ
- ប្រេងសាំងយន្តហោះ (ZA1) 0,២៥ ភាគរយ
- ប្រេងខ្មៅ (FO) 0,១០ ភាគរយ

ប្រការ ២ : ការហួតហើរដូចបានចែងខាងលើ គឺជាការកំណត់បាត់បង់សរុបលើបរិមាណប្រេងឥន្ធនៈនៅលើនាវាឬសាឡង់ ដោយផ្អែកទៅលើ (**ULLAGE REPORT , BILL OF LADING , CARGO MANIFEST**) ។

ប្រការ ៣ : ចំពោះមធ្យោបាយដឹកជញ្ជូនប្រេងឥន្ធនៈទាំងឡាយណា (សាឡង់ ឬ នាវា) ដែលបាត់បង់ប្រេងឥន្ធនៈលើសពីការកំណត់ហួតហើរដែលបានចែងក្នុងប្រការ ១ នឹងត្រូវទទួលធ្វើការផាកពិន័យ ។

ប្រការ ៤ : អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានមន្ទីរ_អង្គភាពពាក់ព័ន្ធ និង ទីចាត់ការ គយ និងរដ្ឋាករ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខានិងត្រា

គាត ឈន់

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣១៨ ប្រក.សហវ.៣៥

ស្តីពីការបំពេញបន្ថែមប្រការ ៤ នៃប្រកាសលេខ ៣៣២ ប្រក.សហវ.៣៥ ចុះថ្ងៃទី០៣ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកាន់បញ្ជីចំណូល_ចំណាយ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តី [illegible] ការ [illegible] មន្ត្រី [illegible] អោយប្រើដោយព្រះ [illegible]
- បានឃើញច្បាប់ស្តី [illegible] សេដ្ឋកិច្ច [illegible] អោយប្រើដោយព្រះ [illegible] ចុះថ្ងៃទី [illegible] ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញមាត្រា ៥១,៥២,៥៣ និងមាត្រា ៥៤ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលចែងអំពីអត្តសញ្ញាណកម្មសហគ្រាសជាប់ពន្ធតាមរបបពិតប្រាកដ និងកាតព្វកិច្ចរដ្ឋបាលរបស់សហគ្រាសជាប់ពន្ធតាមរបបម៉ៅការ
- បានឃើញច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ដែលប្រកាសអោយប្រើដោយព្រះ រាជក្រម នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥

-បានឃើញប្រកាសលេខ ៣៣២ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកាន់បញ្ជីចំណូល-ចំណាយដោយអ្នកជាប់ពន្ធតាមរបបម៉ៅការ

សម្រេច

ប្រការ ១ : ប្រការ ៤ នៃប្រកាសលេខ៣៣២ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការកាន់បញ្ជីចំណូល-ចំណាយ ត្រូវបានកែប្រែនិង បំពេញបន្ថែមដូចខាងក្រោម :

ប្រការ ៤ (ថ្មី) : វិក្កយបត្រដែលបានបង្កើតឡើង ទោះបីដោយសហគ្រាសជាប់ពន្ធអាករតាម របបម៉ៅការដូចបានចែងក្នុងមាត្រា ៥៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ឬ ដោយសហគ្រាសជាប់ពន្ធអាករតាមរបបពិតក៏ដោយ ត្រូវតែមានចុះលេខរៀងរៀបបន្តគ្នាជាលំដាប់ ចាប់ពីថ្ងៃទីមួយរហូតដល់ចុងឆ្នាំ ។ វិក្កយបត្រមួយលេខ ៗ ត្រូវមានពីរសន្លឹក មួយសន្លឹកសំរាប់ប្រគល់ជូនអតិថិជន និងមួយសន្លឹកទៀតសំរាប់រក្សាទុកជាសក្ខីប័ត្រ ។

និទ្ទេសដែលចែងក្នុងវិក្កយបត្រត្រូវមានដូចតទៅ :

-ឈ្មោះ ឬ នាមករណ៍របស់អ្នកលក់ ឬ អ្នកធ្វើសេវា

-អាស័យដ្ឋាន និង លេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់ (បើមាន)

-ឈ្មោះ ឬ នាមករណ៍ព្រមទាំងអាស័យដ្ឋានរបស់អ្នកទិញ

-កាលបរិច្ឆេទបង្កើតវិក្កយបត្រ

-ឈ្មោះទំនិញដែលបានលក់ ឬ សេវាដែលបានធ្វើ

-បរិមាណដែលបានលក់

-ចំនួនប្រាក់ដែលបានទទួល

វិក្កយបត្រត្រូវបង្កើតនៅថ្ងៃប្រគល់ ទទួលទំនិញសំរាប់ការលក់ ។

សំរាប់ការផ្គត់ផ្គង់សេវា កាលបរិច្ឆេទបង្កើតវិក្កយបត្រអាចខុសគ្នា នឹងកាលបរិច្ឆេទធ្វើបាន សំរេចនូវប្រតិបត្តិការផ្គត់ផ្គង់សេវា ។ ក្នុងករណីនេះត្រូវកត់ត្រាបញ្ជាក់ដាក់ក្នុងវិក្កយបត្រនូវកាលបរិច្ឆេទជាក់លាក់នៃ ការធ្វើបាន សំរេចនូវប្រតិបត្តិការផ្គត់ផ្គង់សេវានោះ ។

សំរាប់ការផ្គត់ផ្គង់សេវាដែលមានប្រតិបត្តិការតជាប់ៗគ្នា ត្រូវបង្កើតវិក្កយបត្រជាបន្តបន្ទាប់ទៅតាមប្រតិបត្តិការទាំងឡាយនៃការផ្គត់ផ្គង់សេវា និងត្រូវបង្កើតវិក្កយបត្រនាកាលបរិច្ឆេទ ដែលមានការពិនិត្យកត់ត្រានូវប្រតិបត្តិការទាំងឡាយនៃការផ្គត់ផ្គង់សេវានោះ ។

សំរាប់ការផ្គត់ផ្គង់សេវាដែលអាចនាំអោយកំណត់បានជាស្ថានភាពណាមួយនៃសេវាដែលបានផ្តល់ កាលបរិច្ឆេទដែលត្រូវកត់ត្រាដាក់ក្នុងវិក្កយបត្រគឺជា កាលបរិច្ឆេទធ្វើបាន ហើយស្រេចបាច់នូវការងារដែលស្របទឹងស្ថានភាពនៃសេវាដែលបានផ្តល់នោះ ។

ប្រការ ២ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខានិងត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣១៩ ប្រក.សហវ.ពដ

ស្តីពីនីតិវិធីអនុវត្តសិទ្ធិធ្វើអង្គុត

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាស អោយប្រើដោយព្រះរាជ ក្រម នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញមាត្រា ២៤.៥៤ និង ៥៨ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់ គ្រងឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង មាត្រា ៥៥ ដែលកែប្រែដោយច្បាប់ស្តីពី ការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤
- បានឃើញមាត្រា ៥០.៥១.៥២.៥៣ និងមាត្រា ៥៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលចែងអំពីអត្តសញ្ញាណកម្ម សហគ្រាសជាប់ពន្ធតាមរបបពិតប្រាកដ និង កាតព្វកិច្ចរដ្ឋបាលរបស់ សហគ្រាសជាប់ពន្ធតាមរបបម៉ៅការ
- បានឃើញច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ដែលប្រកាស អោយប្រើដោយព្រះរាជ ក្រម នស.រកម ០៦៩៥.០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥
- បានឃើញបទបញ្ញត្តិទាំងឡាយដែលចែងអំពីកាតព្វកិច្ចឆ្លើយប្រកាសនៃអ្នក ជាប់ពន្ធ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ. ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៣ ស្តីពី កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ
- បានឃើញប្រកាសលេខ ២៦០ ប្រក.សហវ.ពដ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការកំណត់ ពន្ធឡើងវិញក្នុងវិស័យត្រួតពិនិត្យសារ ពើពន្ធ
- បានឃើញប្រកាសលេខ ០៥០ ប្រក.សហវ.ពដ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការដោះស្រាយ បណ្តឹងតវ៉ា
- បានឃើញប្រកាសលេខ ៣១៨ ប្រក.សហវ.ពដ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៦ របស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបំពេញបន្ថែមប្រការ ៤

នៃប្រកាសលេខ ៣៣២ ប្រក.សហវ.ពធ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការកាន់បញ្ជីចំណូល ចំណាយ

សំរេច

ប្រការ ១ : ត្រូវបានកំណត់នូវនីតិវិធី ស្តីពីការអនុវត្តន៍ សិទ្ធិធ្វើអង្កេត ។

ប្រការ ២ : ផ្នែកនៃនាយកដ្ឋានពន្ធដារ ដែលមានសមត្ថកិច្ច ដើម្បីអនុវត្តសិទ្ធិធ្វើអង្កេត គឺ ការិយាល័យអង្កេត និង ផ្តុំពត៌មាន ។

ប្រការ ៣ : ផ្នែកនេះមានសមត្ថកិច្ចថ្នាក់ជាតិ ក្នុងកិច្ចការធ្វើអង្កេតរបស់ខ្លួន ។

ប្រការ ៤ : សិទ្ធិធ្វើអង្កេត អនុញ្ញាតអោយរដ្ឋការពន្ធ ត្រួតពិនិត្យការគោរពប្រតិបត្តិ នូវវិធាន ទាំងឡាយស្តីពី :

- ការធ្វើវិក្កយបត្រ គណនេយ្យកម្ម និង ការរក្សាអោយគង់នូវឯកសារនានា
- អត្តសញ្ញាណកម្ម និង ការចុះបញ្ជីសហគ្រាស
- ការចុះក្នុងបញ្ជិកា នូវប្រតិបត្តិការនានា ដែលជាប់អាករពិសេសលើទំនិញ មួយចំនួន ។

ប្រការ ៥ : ភ្នាក់ងារនៃការិយាល័យអង្កេត និង ផ្តុំពត៌មាន មានសិទ្ធិ :

- តម្រូវអោយសហគ្រាសបង្ហាញដល់ខ្លួន នូវវិក្កយបត្រ គណនេយ្យូបោគុ ក៏ដូច ជាសៀវភៅ បញ្ជិកា ឯកសារ គណនេយ្យនិងវិជ្ជាជីវៈ ទាក់ទិននឹងប្រតិបត្តិការ ដែលបានធ្វើវិក្កយបត្រ ប្រតិបត្តិការដែលជាប់អាករពិសេសលើទំនិញមួយ ចំនួន ឬ ដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិតប្រាកដ និង ទាំងឡាយ ដែលសហគ្រាសត្រូវចុះបញ្ជី
- [illegible]
- តម្រូវអោយសហគ្រាសអោយប្រគល់នូវច្បាប់ចម្លងនៃឯកសារ ដើម្បីជាភស្តុតាង ប្រតិបត្តិការដែលត្រូវបានត្រួតពិនិត្យ
- ទៅដល់ទីកន្លែងសហគ្រាស ឬ កោះអញ្ជើញអ្នកទទួលខុសត្រូវ ឬ អ្នកតំណាង សហគ្រាសមកការិយាល័យរបស់ខ្លួន ដើម្បីធ្វើសវនកម្ម ។

ប្រការ ៦ : ក្នុងពេលម៉ោងអាជីវកម្ម ភ្នាក់ងារនៃការិយាល័យអង្កេត និង ផ្តុំពត៌មាន មានសិទ្ធិ ចូលទៅខាងក្នុងនៃអាគារ ដីធ្លី ភណ្ឌាគារ ទាំងអស់របស់សហគ្រាស ព្រមទាំងមាន សិទ្ធិត្រួតពិនិត្យមធ្យោបាយដឹក ជញ្ជូនប្រើប្រាស់សំរាប់កិច្ចការអាជីវកម្ម និង ការ

ផ្ទុករបស់មធ្យោបាយដឹកជញ្ជូនទាំងនោះ ។

ប្រការ ៧ : នៅពេលធ្វើអន្តរាគមន៍លើកទីមួយ ភ្នាក់ងារនៃការិយាល័យអង្កេត និង ផ្ទុំពតិមាន ត្រូវប្រគល់ជូនសហគ្រាសនូវលិខិតជូនដំណឹងស្តីពីការធ្វើអង្កេត ។ លិខិតជូនដំណឹងនេះ ត្រូវធ្វើឡើងជាពីរច្បាប់មួយច្បាប់ទុកនៅសហគ្រាស មួយច្បាប់ទៀតរក្សាទុកដោយអង្គការពន្ធ ។

កាលបើការធ្វើអន្តរាគមន៍លើកទីមួយ ប្រព្រឹត្តទៅដោយអវត្តមាននៃអ្នកទទួលខុសត្រូវសហគ្រាស អ្នកតំណាងស្របច្បាប់នៃនីតិបុគ្គល ឬ ប្រធានសហគ្រាសឯកត្តជន " លិខិតជូនដំណឹងស្តីពីការធ្វើអង្កេត ត្រូវប្រគល់ជូនអ្នកដែលបានជួបធ្វើការជាមួយភ្នាក់ងារនៃ ការិយាល័យអង្កេត និង ផ្ទុំពតិមាន ។

ប្រការ ៨ : អន្តរាគមន៍នីមួយៗ គឺជាកម្មវត្ថុនៃការធ្វើកំណត់ហេតុដែលកត់ត្រាពិស្តារអំពីប្រតិបត្តិការនានាដែលបានធ្វើ ។

សវនកម្មនីមួយៗ សុទ្ធតែត្រូវកត់ត្រាចូលក្នុងកំណត់ហេតុ ។

កាលបើការធ្វើអន្តរាគមន៍លើកទីមួយ ប្រព្រឹត្តទៅដោយអវត្តមាន នៃអ្នកទទួលខុសត្រូវសហគ្រាស "អ្នកតំណាងស្របច្បាប់នៃនីតិបុគ្គល ឬ ប្រធានសហគ្រាសឯកត្តជន" ភ្នាក់ងារនៃការិយាល័យអង្កេត និង ផ្ទុំពតិមាន ត្រូវធ្វើកំណត់ ហេតុជាបន្ទាន់ ជាពីរច្បាប់ ។ កំណត់ហេតុនេះ ត្រូវចុះហត្ថលេខាដោយភ្នាក់ងារ នៃ ការិយាល័យអង្កេត និង ផ្ទុំពតិមាន និង អ្នកដែលមានវត្ត មានក្នុងដំណើរប្រព្រឹត្តទៅនៃប្រតិបត្តិការ ។ ក្នុងករណី ប្រកែកមិនព្រមចុះហត្ថលេខា ហេតុការណ៍នេះ ត្រូវចុះចូលក្នុងកំណត់ហេតុ ។

កំណត់ហេតុមួយច្បាប់ ត្រូវបញ្ជូនទៅអោយអ្នកទទួលខុសត្រូវសហគ្រាស " អ្នកតំណាងស្របច្បាប់នៃនីតិបុគ្គល ឬ ប្រធានសហគ្រាសឯកត្តជន " និងមួយច្បាប់ ទៀតរក្សាទុកដោយអង្គការពន្ធ ។

ប្រការ ៩ : នៅពេលបញ្ចប់ការធ្វើអង្កេត ភ្នាក់ងារនៃការិយាល័យអង្កេត និង ផ្ទុំពតិមាន ត្រូវធ្វើកំណត់ហេតុអំពីការប្រព្រឹត្តិខុសឆ្គងពិនិត្យឃើញ ឬ ការមិនបានប្រព្រឹត្តខុសឆ្គងរបស់សហគ្រាស ។

ក្នុងករណីដែលច្បាប់ចម្លងឯកសារ ត្រូវបានប្រគល់អោយភ្នាក់ងារនៃការិយាល័យអង្កេត និង ផ្ទុំពតិមានៗ ត្រូវធ្វើបញ្ជីរាយមុខឯកសារទាំងនោះ ភ្ជាប់ជា

ឧបសម្ព័ន្ធនិងកំណត់ហេតុ ។

កំណត់ហេតុនេះ ត្រូវធ្វើក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីអន្តរាគមន៍ដល់ទីកន្លែងចុងក្រោយ ឬ ការកោះអញ្ជើញចុងក្រោយ ដែលត្រូវបានចុះហត្ថលេខាដោយភ្នាក់ងារនៃការិយាល័យអង្កេត និង ផ្ទុំពតិមាន និង អ្នកទទួលខុសត្រូវសហគ្រាស "អ្នកតំណាងស្របច្បាប់នៃនីតិបុគ្គលឬ ប្រធាន សហគ្រាសឯកត្តជន" ។

ក្នុងករណីប្រកែកមិនព្រមចុះហត្ថលេខា ហេតុការណ៍នេះត្រូវចុះចូលក្នុងកំណត់ហេតុ ។

កំណត់ហេតុត្រូវធ្វើឡើងជាពីរច្បាប់ មួយច្បាប់ប្រគល់ជូនសហគ្រាស និង មួយច្បាប់ទៀតរក្សាទុកដោយអង្គការពន្ធ ។

ប្រការ ១០ : ការពិនិត្យកត់ត្រាក្នុងកំណត់ហេតុ ត្រូវបានប្រើការប្រឈមទល់នឹងសហគ្រាសសំរាប់ការកំណត់ពន្ធគ្រប់ប្រភេទ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យសារពើពន្ធ ។

ប្រការ ១១ : ក្នុងករណីមានរឿងវិវាទ ទាក់ទិននឹងការប្រព្រឹត្តិទៅនៃប្រតិបត្តិការអង្កេត សហគ្រាសត្រូវ ធ្វើពាក្យបណ្តឹងតវ៉ា ទៅអង្គការពន្ធដែលមានលំដាប់ថ្នាក់ខ្ពស់ជាងផ្នែកដែលបានទៅធ្វើអង្កេត ក្នុងរយៈពេលពីរខែ បន្ទាប់ពីកាលបរិច្ឆេទនៃប្រតិបត្តិការ ។

ប្រការ ១២ : អំពើប្រមាថនិងអំពើហិង្សាទាំងឡាយ ប្រព្រឹត្តចំពោះភ្នាក់ងារដែលធ្វើអង្កេត ព្រមទាំងរាល់អំពើប្រឆាំងផ្សេងទៀត គឺជាកម្មវត្ថុនៃការធ្វើកំណត់ហេតុ ។ អ្នកប្រព្រឹត្តអំពើនេះជា កម្មវត្ថុនៃបណ្តឹងព្រហ្មទណ្ឌ ដែលស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ១៣ : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣២៣ ប្រក.សហវ.គរ

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរា ជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ តុលា ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជ ក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញ សារាចរស្តីពីការគ្រប់គ្រងមន្ត្រីរាជការគយនិងរដ្ឋាករ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ០០១ សរ.សហវ.គរ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥
- បានឃើញព្រះរាជសាររបស់សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦
- យោងការងារចាំបាច់របស់ក្រសួង ។

សំរេច

ប្រការ ១ : តែងតាំងលោក **ខៀវ សារឿន** បច្ចុប្បន្នជាអនុប្រធានស្នាក់ការគយរដ្ឋាករកំពង់ផែក្រុងព្រះសីហនុ ជាអនុប្រធានការិយាល័យគយនិងរដ្ឋាករ ផែស្វួត ។

ប្រការ ២ : អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក នាយកទីចាត់ការគយនិងរដ្ឋាករ និង សាមីខ្លួន ដូចប្រការ១ខាងលើត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
គាត ឈន់

* * *

២– ឯកសារក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាសលេខ ៥០០ ឧក.ប្រក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ លី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៤១២០ ភ.ព ចុះថ្ងៃទី១៦ - ០២ - ៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៥០ ផ្លូវត្រសក់ផ្អែម សង្កាត់ចតុមុខ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហម្មតូច ផលិត ពោះវៀនកង់ - ម៉ូតូ នៅក្នុងទីតាំង ផ្ទះសង់ថ្មី ផ្លូវទួលសង្កែ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **សុខ លី** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលពោះវៀនកង់–ម៉ូតូ សញ្ញា « សំពៅ » ស្របតាមគំរូ និង សញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាពល្អ មិនធានាក្នុងការប្រើប្រាស់ ឬបង្កអោយមានការប៉ះពាល់ដល់ បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០១ ផក.ប្រក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ម៉ិល ស៊ីម៉េង** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១១៥៥៥៧ ប.ប ចុះថ្ងៃទី ០៧-៩-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ថ្មគោល ឃុំ តាពូង ស្រុក បាត់ដំបង ខេត្តបាត់ដំបង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **ម៉ិល ស៊ីម៉េង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០២ ផក.ប្រក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ិល មខុន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០១០៧៧ ប.ប ចុះថ្ងៃទី ០២-៨-៩០ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ថ្មគោល ឃុំ តាពូង ស្រុក បាត់ដំបង ខេត្តបាត់ដំបង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣៧ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ម៉ិល មខុន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥០៣ ផឧ.ប្រក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **សោម សុខុម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥៣១០៦ ភ.ព ចុះថ្ងៃទី ០២–០២–៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៤ អឺ០ ផ្លូវលេខ ១០៦ សង្កាត់វត្តភ្នំខណ្ឌដូនពេញ រាជធានីភ្នំពេញ បើកដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៨០ សេះ នៅក្នុងទីតាំងភូមិ ជ្រៃចាស់ ឃុំជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **សោម សុខុម** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ ១ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៣– ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៨៦

ប្រកាសលេខ ៧០១ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ព

សៀវភៅជីវវិទ្យាសំរាប់គ្រូថ្នាក់ទី ៧

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតីចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤–៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រម នស / រកម /០១៩៦ /០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

– បានពិនិត្យលិខិតឧទ្ទេសនាមលេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ

– បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅជីវវិទ្យាសំរាប់គ្រូថ្នាក់ទី ៧ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅជីវវិទ្យាសំរាប់គ្រូ ថ្នាក់ទី ៧ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការជីវវិទ្យា មធ្យមសិក្សានៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំ យុវជន និង កីឡា រៀបរៀងដោយអ្នកស្រី **ឆាន សោភ័ណ** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំនេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និងត្រា

តូល ឡោះ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៧០២ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ព

សៀវភៅភាសាខ្មែរសំរាប់សិស្សថ្នាក់ទី ៧

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតីចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃ ៣១-ខែតុលា ឆ្នាំ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស / រកម /០១៩៦ /០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានពិនិត្យលិខិតឧទ្ទេសនាមលេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅភាសាខ្មែរសំរាប់សិស្សថ្នាក់ទី ៧ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅភាសាខ្មែរសំរាប់សិស្ស ថ្នាក់ទី ៧ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការភាសាខ្មែរ មធ្យមសិក្សានៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំ យុវជន និង កីឡា រៀបរៀង ដោយលោក **លី សុមុនី** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំនេះទូទៅ និងមន្ត្រីយ៍សិក្សាមានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
គួល ឡោះ

* * *

៤—ទីស្ដីការក្រសួងធម្មការ និង សាសនា

សេចក្ដីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៨៦

សេចក្ដីសំរេចលេខ ១៥៧ ៨៦ ក.ធ .ស.
អនុញ្ញាតជាគោលការណ៍ អោយមានព្រះវិហារឈ្មោះ
« សាមរឿង »

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៨៣
– បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស រកម –០១៨៦–១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៨៦ ។

-បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ : ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៤ ។

-បានឃើញអនុក្រឹត្យលេខ: ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ ៦ ឆ្នាំ១៩៩២ ដែលរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងធម្មការនិងសាសនា ។

-បានឃើញពាក្យសុំបើកព្រះវិហារចិនឈ្មោះ " **សាមអ៊ួង** " ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍ អោយមានព្រះវិហារចិនឈ្មោះ" **សាមអ៊ួង**" មួយកន្លែង ដែលមានទីតាំងស្ថិតនៅភូមិពន្លា សង្កាត់ព្រែកប្រា ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ព្រះវិហារចិនឈ្មោះ " **សាមអ៊ួង**" ដែលគោរពបូជាព្រះ សាមកុង ត្រូវអនុញ្ញាត អោយផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ព្រះវិហារចិនឈ្មោះ" **សាមអ៊ួង**" ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំព្រះវិហារត្រូវមានសាមគ្គីភាព និងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តផ្ទុយពី សេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ប្រការ ៥ : នាយកដ្ឋានសាសនា-មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសការណ៍អនុវត្ត សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហ៊ឿន វណ្ណារ័ត្ន

* * *

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៥៧០ រៀល